គណបក្ស សិទ្ធិមនុស្ស
HUMAN RIGHTS PARTY
បំរើ ការពារ កសាង

កើតពីប្រជាពលរដ្ឋ របស់ប្រជាពលរដ្ឋ ដើម្បីប្រជាពលរដ្ឋ

ព្រឹត្តិប័ត្រព័ត៌មានប្រចាំសប្តាហ៍ ថ្ងៃសុក្រ ទី២៤ ខែមេសា ឆ្នាំ២០០៩ ព្រឹត្តិប័ត្រលេខ៨១ ឆ្នាំទី២


| មាតិកាព័ត៌មាន | ទំព័រ |
|---|---|
| -ប្រជាពលរដ្ឋនៅខេត្តតាកែវព្រួយបារម្ភខ្លាចធនាគាររឹបអូសផ្ទះ | ១ |
| -ថ្នាក់ដឹកនាំគណបក្សសិទ្ធិមនុស្សចុះសំណេះសំណាលជាមួយប្រជាពលរដ្ឋខេត្តស្វាយរៀង | ២ |
| -អាជ្ញាធរខេត្តកំពង់ស្ពឺជំរិតទារប្រាក់ប្រជាពលរដ្ឋចំនួន៤០០០ដុល្លារ | ៣ |
| -ប្រជាពលរដ្ឋសហគមន៍រីករាយកំពុងមានការព្រួយបារម្ភពីបញ្ហាអនាម័យ | ៤ |


## ប្រជាពលរដ្ឋនៅខេត្តតាកែវព្រួយបារម្ភខ្លាចធនាគាររឹបអូសផ្ទះ

ប្រជាពលរដ្ឋរស់នៅឃុំក្តាញ់ ស្រុកព្រៃកប្បាស ខេត្តតាកែវ បានធ្វើការត្អូញត្អែរពីការដែលពួកគាត់បានខ្ចីលុយពីធនាគារប្រកបរបរត្បាញវៃ ប៉ុន្តែឥឡូវនេះមុខរបរត្បាញវៃរបស់គាត់បាត់បង់ទីផ្សារ ឬក៏ផលិតផលត្រូវបានគេបន្ថោក ។

លោក **ម៉ុក រាយ** រស់នៅឃុំក្តាញ់ ស្រុកព្រៃកប្បាសបានបញ្ជាក់ថា ប្រជាពលរដ្ឋប្រមាណ ៤០-៧០ ភាគរយ ដែលរស់នៅឃុំក្តាញ់បានខ្ចីលុយពីធនាគារអេស៊ីលីដា អម្រឹត និង ធនាគារផ្សេងទៀតដើម្បីប្រកបរបរត្បាញហូលផាមួង ដែលបានកាលពីមុនរបរត្បាញហូលអាចជួយឱ្យជីវភាពរស់នៅរបស់អ្នកភូមិបានធូរធារមួយកំរិត ប៉ុន្តែឥឡូវនេះមុខរបរ អាជីពត្បាញហូលរបស់ពួកគាត់បាត់បង់ទីផ្សារដូចជា ហូលមួយក្បិនថ្លៃ ៣០-៤០ដុល្លារ ខុសកាលពីមុនមួយក្បិនថ្លៃ ៧០ -៨០ដុល្លារផងក៏មាន ។

លោកបានបន្តថា ប្រជាកសិករនៅភូមិក្តាញ់ ភូមិក្បៀម ភូមិត្រពាំងល្វា ភូមិក្រាំងពេជ្រ ភូមិអង្គ ភូមិក្រាំងស្វាយ អ្នកភូមិទាំងនេះសុទ្ធតែខ្ចីលុយពីធនាគារ ដើម្បីប្រកបរបរត្បាញវៃ ឬប្រកបមុខរបរផ្សេងៗទៀត ។ កាលពីមុននេះប្រជាកសិករក៏បានខ្ចីលុយគាត់ពីធនាគារផងដែរតែសេដ្ឋកិច្ចនៅដើរល្អ មិនមានផលវិបាកនោះទេ ឥឡូវវិបត្តិសេដ្ឋកិច្ចធ្លាក់ចុះធ្វើឱ្យជីវភាពរស់នៅរបស់ពួកគាត់ធ្លាក់ចុះ ។

សិប្បករ **មូល ច័ន្ទ** រស់នៅភូមិក្បៀម ឃុំក្តាញ់បានឱ្យដឹងថា អ្នកភូមិក្បៀមជាង៣០០គ្រួសារប្រកបរបរត្បាញ ហូលតំណរពីដូនតា និងជាការងារបន្ទាប់បន្សំពីកិច្ចការស្រែចំការ ។ ការប្រកបរបរត្បាញហូលភាគច្រើនអ្នកភូមិខ្ចីលុយ ពីធនាគារដើម្បីធ្វើជាដើមទុនក្នុងការរកស៊ី ។ សំរាប់អ្នកស្រី **មូល ច័ន្ទ** ក៏បានខ្ចីលុយពីធនាគារអេស៊ីលីដា ១,០០០ ដុល្លារ ហើយគាត់ត្រូវសងការប្រាក់ទាំងចុងទាំងដើមក្នុង១ខែ ជាង ១០០ដុល្លារឯណោះ ។

អ្នកស្រីបានគូសបញ្ជាក់ថា តំលៃហូលទើបតែធ្លាក់ចុះរវាង ២- ៣ ខែប៉ុណ្ណោះដែលកាលពីមុនតំលៃហូលតំលៃគួរសម ។ ទោះបីយ៉ាងណាក៏ដោយអ្នកស្រី **មូល ច័ន្ទ** ដែលចាប់យកអាជីពត្បាញ

ហួលជាមួងអស់រយៈពេលជាង ២០ឆ្នាំទៅហើយ នោះនៅតែបង្ហាញក្តីកង្វល់ដោយខ្លាចក្រែង ធនាគាររឹបអូសយកដីធ្លីផ្ទះសំបែងរបស់គាត់ខណៈពេលជីវភាពរស់នៅសព្វថ្ងៃ របស់អ្នកស្រីកំពុងប្រឈមមុខនឹងភាពខ្វះខាតផងនោះ ។

លោក **កឹម សុខា** ប្រធានគណបក្សសិទ្ធិមនុស្ស ឬគណបក្សមិនរណបមានប្រសាសន៍ថា បញ្ហាវិបត្តិសេដ្ឋកិច្ចធ្ងន់ធ្ងរមកលើប្រជាពលរដ្ឋខ្មែរជាពិសេសប្រជាកសិករ ។ ទន្ទឹមនឹងនេះលោកក៏បានធ្វើសំណើ២ដងរួចមកហើយដាក់ជូនរដ្ឋាភិបាល ប៉ុន្តែរដ្ឋាភិបាលមិនទាន់ដោះស្រាយជូនប្រជាពលរដ្ឋនៅឡើយទេ ។ បញ្ហាប្រជាពលរដ្ឋនៅស្រុកព្រៃកប្បាស ដែលខ្ចីលុយពីធនាគារដើម្បីប្រកបរបរត្បាញហូល ហើយឥឡូវនេះជិតដល់វេនគេរឹបអូសយកដីធ្លីផ្ទះសំបែងរបស់គាត់ ។ លោកជាប្រជាពលរដ្ឋមិនមែនគេចវេះមិនសងលុយគាត់ទៅធនាគារនោះទេ ប៉ុន្តែផលិតផលគ្មានទីផ្សារ ឬតំលៃចុះថោកបញ្ហានេះ ក៏ជាការទទួលខុសត្រូវមួយផ្នែករបស់រដ្ឋាភិបាលផងដែរដើម្បីជួយសំរួលរឿងនេះ ។

លោក **កឹម សុខា** អ្នកតំណាងរាស្ត្រមណ្ឌលកំពង់ចាមបានបន្ថែមថា វិបត្តិសេដ្ឋកិច្ចសកលលោកប៉ះពាល់ធ្ងន់ធ្ងរណាស់សំរាប់កម្ពុជាថា ពោលប្រជាពលរដ្ឋជាង៣០ភាគរយដែលរស់ក្រោមបន្ទាត់នៃភាពក្រីក្រហើយរកមិនបាន ១ដុល្លារផងក្នុងមួយថ្ងៃ ។

លោក **កង លី** មេឃុំក្តាញ់បានអះអាងថា នៅក្នុងឃុំក្តាញ់ មាន៧ភូមិហើយប្រជាពលរដ្ឋសុទ្ធតែប្រកបរបរ ត្បាញហូលក្នុងចំណោម៧ភូមិមានភូមិ២ក្តាញ់ និងភូមិក្បៀម ប្រជាពលរដ្ឋខ្ចីលុយពីធនាគារជាច្រើន ប៉ុន្តែពេលនេះតំលៃហូលរបស់អ្នកស្រុកចុះថោកធ្វើប៉ះពាល់ដល់ជីវភាពរស់នៅរបស់ពួកគាត់ ។ រហូតមកដល់ពេលនេះមិនទាន់មានធនាគារណាមួយ រឹបអូសយកដីធ្លីផ្ទះសំបែងអ្នកភូមិនៅឡើយទេគ្រាន់តែធនាគារជំរុញឲ្យគាត់សងបំណុលតែប៉ុណ្ណោះ ។

## ថ្នាក់ដឹកនាំគណបក្សសិទ្ធិមនុស្សចុះសំណេះសំណាលជាមួយប្រជាពលរដ្ឋខេត្តស្វាយរៀង

អនុប្រធានគណៈកម្មាធិការប្រតិបត្តិខេត្តស្វាយរៀងរបស់គណបក្សសិទ្ធិមនុស្សបានថ្លែងប្រាប់ថា ប្រជាពលរដ្ឋនៅខេត្តស្វាយរៀងមានការគាំទ្រគណបក្សសិទ្ធិមនុស្សច្រើនជាងកាលពីឆ្នាំ២០០៨។

លោកបានបន្តទៀតថា អាជ្ញាធរដែនដីនៅតែតាមលងឈ្លបយកការណ៍ពីប្រជាពលរដ្ឋ គំរាមកំហែងប្រជាពលរដ្ឋ តួយ៉ាងដូចជានៅពិធីសំណេះសំណាលនៅថ្ងៃទី២៥ ខែមេសា ឆ្នាំ២០០៩នេះជាដើម គឺអាជ្ញាធរមានសមត្ថកិច្ចនៅឈរយាមផ្លូវសងខាង មានសៀវភៅកត់ឈ្មោះប្រជាពលរដ្ឋ ដែលទង្វើបែបនេះលោកយល់ថាជាការគំរាមកំហែងដល់ប្រជាពលរដ្ឋដែលបានមកចូលរួមវេទិកានេះ ។

សកម្មជនគណបក្សសិទ្ធិមនុស្ស នៅឃុំដូង ស្រុករមាសហែកបានឲ្យដឹងថា ប្រជាពលរដ្ឋនៅឃុំដូង ជួបការលំបាកជាមួយជនជាតិយួន ជាពិសេសអាជីវករនៅផ្សារកំពង់ត្រឡាច ដោយសារនៅផ្សារកំពង់ត្រាចមាន អាជីវករខ្មែរហាក់ព្រងើយកន្តើយអំពីបញ្ហានេះ ។

នៅស្រុករមាសហែកមាន១៦ឃុំ ក្នុងនោះឃុំដូង ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋជួបការលំបាកជាប់បណ្តាយឃុំនានា។

លោក **កឹម សុខា** ប្រធានគណបក្សសិទ្ធិមនុស្ស មានប្រសាសន៍ទៅកាន់ប្រជាពលរដ្ឋ សកម្មជនគណបក្សសិទ្ធិមនុស្សនៅឃុំដូងក្នុងស្រុករមាសថាខ្មែរណាក៏ដោយ ក៏ជាខ្មែរទោះបីគណបក្សប្រជាជន គណបក្សសមរង្ស៊ី គណបក្សហ៊្វុនស៊ិនប៉ិចក៏ជាខ្មែរ ។ សំខាន់នោះត្រូវគិតថា បើខ្មែរយើងបែកបាក់គ្នានឹងបាត់បង់ទឹកដីហើយពេលណាខ្មែររួមគ្នាខ្មែរពិតជាការពារទឹកដីបាន ។ លោកបានបញ្ជាក់បន្ថែមទៀតថា ប្រការដែលយើងមានថ្នល់ជាតិមន្ទីរពេទ្យសាលារៀនមិនមែនដោយសារ ៧មករា ឆ្នាំ១៩៧៩ នោះទេពោល

គឺដោយសារ ២៣តុលា ឆ្នាំ១៩៩១ ហើយកិច្ចព្រមព្រៀងនៅក្រុងប៉ារីស ប្រទេសបារាំង គឺសហគមន៍អន្តរជាតិគេសន្យាជួយប្រទេសខ្មែរ ។ ក្នុងមួយឆ្នាំៗគេផ្តល់ជំនួយរាប់ពាន់លានដុល្លារដើម្បីកសាងប្រទេសជាតិ ។ មិនមែនដូចគណបក្សប្រជាជនថាកសាងប្រទេសពីបាតដៃទទេនោះឡើយ ។

លោក **កឹម សុខា** បានគូសបញ្ជាក់ថា គណបក្សសិទ្ធិមនុស្សមិនយកខ្មែរណាជាសត្រូវ ខ្មែរណាក៏ជាខ្មែរ ហើយក៏មិនមែនយកបរទេសជិតខាងណាធ្វើជាសត្រូវ ប៉ុន្តែត្រូវតែគោរពគ្នាទៅវិញទៅមក ។ លោក **កឹម សុខា** បានប្រមើរមើលឃើញថា សព្វថ្ងៃនេះប្រទេសកម្ពុជាយើងមិនទាន់មាន លទ្ធិប្រជាធិបតេយ្យឱ្យនៅបានត្រឹមត្រូវបញ្ហាជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅតែក្រ ។ ប្រទេសកម្ពុជាជាប្រទេសដែលក្រីក្រ នៅលើពិភពលោកដែលប្រជាពលរដ្ឋរកចំណូលមិនបាន១ដុល្លារផងក្នុងមួយថ្ងៃគ្រានេះមានជាង៣០% ។

## អាជ្ញាធរខេត្តកំពង់ស្ពឺជំរិតទារប្រាក់ប្រជាពលរដ្ឋចំនួន៤០០០ដុល្លារ

អាណាព្យាបាលយុវជន ៣នាក់ នៅភូមិសីរី ឃុំកោះធំ ស្រុកច្បារមន ខេត្តកំពង់ស្ពឺ បានចោទប្រកាន់អធិការស្រុកច្បារមនថា គាបយកលុយពីគ្រួសារពួកគាត់ចំនួន ៤០០០ដុល្លារជាថ្នូរ នឹងការមិនចាប់ខ្លួនពួកគេ ។

ស្ត្រីជាម្តាយយុវជនម្នាក់ក្នុងចំណោម៣នាក់ដែលត្រូវបានលោក **ជួរ ហេង** ម្ចាស់សិប្បកម្មផ្សារដែកនៅភូមិស្តើទី២ ប្តឹងចោទប្រកាន់បានបង្ហើបប្រាប់ថា កូនគាត់ឈ្មោះ **សុខ ជា** អាយុ១៨ឆ្នាំ បានចូលរួមពិធីរាំវែកនៅផ្ទះមិត្តភ័ក្តរបស់គេមុន បុណ្យចូលឆ្នាំស្រាប់តែមានក្រុមក្មេងៗ នៅក្នុងសិប្បកម្មផ្សារដែករបស់លោក **ជួន ហេង** កើតមានការប្រទូស្តរាយគប់ដុំថ្មគ្នាទៅវិញទៅមករហូតមានភាគីខាងយុវជន៣នាក់រងរបួសបែកក្បាល ។

ស្ត្រីជាម្តាយយុវជនរូបនោះបានបន្តទៀតថា ក្រោយមកលោក **ជួរ ហេង** បានដាក់ពាក្យបណ្តឹងចោទប្រកាន់កូនរបស់គាត់និងមិត្តភ័ក្រគេ២នាក់ផ្សេងទៀត ។ មកដល់ពេលនេះអធិការដ្ឋាននគរបាលស្រុកច្បារមនបានកោះហៅកូនគាត់ឱ្យចូលខ្លួន ២-៣ លើករួចមកហើយ ប៉ុន្តែគាត់មិនឱ្យកូនចូលខ្លួននោះទេដោយខ្លាចក្រែងសមត្ថកិច្ចចាប់ខ្លួនកូនគាត់ពីព្រោះ កន្លងមកក្មេងដែលមានបញ្ហាដូចកូនគាត់នៅពេលដែលទៅចូលខ្លួន តែងតែចាប់ដាក់ឃុំឃាំង ។

យុវជនជំទង់ឈ្មោះ **គង់ បញ្ញា** អាយុ១៧ឆ្នាំ បាននិយាយថា ភាគីកូនជាងផ្សារដែកនៅសិប្បកម្មផ្សារដែកអង្គសិរិបាន បង្ករឿងរ៉ាវមកលើពួកគេមុនពេលរាំវង់កាលពីរាត្រីថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៩ ហើយពួកគេម្នាក់រងរបួសបែកក្បាល ។

លោក **ធួន សាង** ម្ចាស់សិប្បកម្មផ្សារដែកនៅភូមិស្តើទី២ ឃុំរកាធំ បានឱ្យដឹងថាកូនជាងរបស់គាត់នៅពេល ឃើញគេរាំវែកនៅខាងមុខរោងសិប្បកម្មដែលស្ថិតនៅម្ខាងផ្លូវជាតិ ។ ចំណែកកូនជាងផ្សារដែកទាំងនោះ ក៏បានទៅចូលរួមក្នុងពិធីសំណេះសំណាលផងដែរ ក្រោយមកទើបមានការគប់ចោលដុំថ្មចុះឡើងៗ បណ្តាលឱ្យផ្ទុះធ្លាយរោង និងស្លាកយីហោសិប្បកម្មរបស់គាត់ ។

លោក **ធុន ហេង** ដែលបានដាក់ពាក្យបណ្តឹងចោទប្រកាន់យុវជន៣នាក់ឈ្មោះ **សុខ ជា គង់ បញ្ញា** និងឈ្មោះ **មៅ** បានបន្តថា គាត់ប្តឹងចោទប្រកាន់យុវជន៣នាក់ថា បានបំផ្លាញទ្រព្យសម្បត្តិរបស់គាត់ឱ្យខូចខាត ។

អាណាព្យាបាលរបស់យុវជន **គង់ បញ្ញា** បានលើកឡើងថា ក្រុមកូនរបស់គាត់រងគ្រោះបែកក្បាលគាត់មិនបានប្តឹងប្តល់ ទេប៉ុន្តែបែរជាគេប្តឹងទៅវិញ ។

ជានិច្ចកាលគេតែងតែលេចឮពតិមានសមត្ថកិច្ច ប៉ូលិសដែលដោះស្រាយជំលោះបណ្តឹង ច្រើនតែគាបសង្កត់ជំរិតទារលុយពីភាគីរងគ្រោះដើម្បីជាថ្នូរនឹងការដោះលែងឬ ក៏ជាថ្នូរនឹងការមិន

ចាប់ខ្លួន ។ ដែលទង្វើរបែបនេះវាកំពុងក្លាយទៅជាប្រពៃណីពេញនិយមដែលសមត្ថកិច្ចតែងបានគោរពប្រតិបត្តិស្ទើរមិនលស់ពេល ។

## ប្រជាពលរដ្ឋសហគមន៍រីករាយកំពុងមានការព្រួយបារម្ភពីបញ្ហាអនាម័យ

លោក **សំ សំអាត** មន្ត្រីស៊ើបអង្កេតនៃអង្គការលីកាដូបានបញ្ជាក់ថា ចាប់តាំងពីឆ្នាំ១៩៩០ រហូតមកដល់សព្វថ្ងៃនេះ ប្រជាពលរដ្ឋដែលត្រូវបានអាជ្ញាធរក្រុង ជម្លៀសចេញឱ្យទៅរស់នៅជាយក្រុងនេះពួកគាត់ប្រឈមមុខនឹងផលវិបាក ដូចជាការរស់នៅមានទីតាំងឆ្ងាយទឹកប្រើប្រាស់កង្វះអនាម័យ ។

ជារឿយៗការអភិវឌ្ឍន៍របស់សាលាក្រុងភ្នំពេញដោយបានជម្លៀសប្រជាពលរដ្ឋឱ្យរស់នៅជាយក្រុងភ្នំពេញ បណ្តោយឱ្យពួកគាត់ពិបាកក្នុងជីវភាពរស់នៅ ឆ្ងាយពីកន្លែងធ្វើការងារ បញ្ហាកូនចៅទៅសាលារៀន ទាំងនោះធ្វើឱ្យពួកគាត់ កាន់តែពិបាកជាងកាលដែលគាត់រស់នៅកណ្តាលក្រុងភ្នំពេញទៀត ។ លោក **សំ សំអាត** បានគូសបញ្ជាក់ទៀតថាគំរោង និងការអភិវឌ្ឍន៍របស់សាលាក្រុងភ្នំពេញធ្វើឡើងដោយបង្ខំ និងគ្មានការគិតគូរឱ្យបានវែងឆ្ងាយសំរាប់ផលប្រយោជន៍ប្រជាពលរដ្ឋ ។

លោក **ច័ន្ទ សុវេត** មន្ត្រីស៊ើបអង្កេតជាន់ខ្ពស់នៃសមាគមអាដហុកការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា បានបង្ហើបឱ្យដឹងថាបញ្ហាសំណង និងការរៀបចំទីតាំងរស់នៅសមរម្យ សំរាប់ប្រជាពលរដ្ឋដែលអាជ្ញាធរក្រុង ជម្លៀសនៅមិនទាន់បានគត់មុត ដែលអាចទទួលយកបាននៅឡើយទេ សង្គមស៊ីវិលមានការព្រួយបារម្ភខ្លាំងណាស់ប្រសិនបើស្ថិតក្នុងដំណាក់កាលបណ្តេញ ចេញដោយបង្ខំ ក្នុងនោះសង្គមស៊ីវិល សូមស្នើយ៉ាងទទូចសូមបញ្ឈប់ជាបន្ទាន់ចំពោះបញ្ហានេះ ។ ម្យ៉ាងទៀតអាជ្ញាធរត្រូវតែរៀបចំដោះស្រាយដោយសន្តិវិធី និងឱ្យមានលក្ខណៈសិទ្ធិសេរីភាពដែលប្រជាពលរដ្ឋដែលអាចទទួលយកបាន ។

លោក **ប៉ែន សុវណ្ណ** ប្រធានគណៈកម្មាធិការវិន័យរបស់គណបក្សសិទ្ធិមនុស្សបានថ្លែងប្រាប់តាមទូរស័ព្ទខណៈ ពេលលោកមានវត្តមាននៅទឹកដីស្រុកបរិបូរណ៍ខេត្តកំពង់ឆ្នាំង ថាការដែលជំលៀសប្រជាពលរដ្ឋ នៅក្រុងភ្នំពេញកើតមានខ្លាំងនោះគឺនៅ ឆ្នាំ១៩៩២ រហូតមកដល់បច្ចុប្បន្ន ។

សូមរំឭកថា ការជម្លៀសប្រជាពលរដ្ឋនៅកណ្តាលក្រុងភ្នំពេញឱ្យទៅរស់នៅជាយក្រុងភ្នំពេញ ត្រូវបានអាជ្ញាធរក្រុងភ្នំពេញជម្លៀសប្រជាពលរដ្ឋជាសហគមន៍តួយ៉ាង សហគមន៍សំបុកចាប សហគមន៍ប្រជាពាសាសន៍នៅសង្កាត់ជ្រោយចង្វា សហគមន៍បុរីកីឡា សហគមន៍ដីក្រហម ហើយសហគមន៍បឹងកក់ថ្មី ឥឡូវគឺសហគមន៍រីករាយនៅសង្កាត់ទន្លេបាសាក់ ។ រាល់ការជម្លៀសប្រជាពលរដ្ឋឱ្យចាកចេញកណ្តាលក្រុង ឱ្យទៅរស់នៅជាយក្រុងភ្នំពេញគឺធ្វើឡើងក្រោមការឈឺចាប់ និងដំណក់ទឹកភ្នែករបស់ប្រជាពលរដ្ឋ ។


| គ្រប់គ្រងការផ្សព្វផ្សាយ | | |
|---|---|---|
| **លោក** | **ម៉ី សាន** | ទូរស័ព្ទលេខ: ០១១ ៩០៤ ០៣១ |
| **កញ្ញា** | **គង់ វណ្ណា** | ទូរស័ព្ទលេខ: ០១២ ៨៦៥ ២៩៥ |
| ផ្ទះលេខ៧២-៧៤,ផ្លូវលេខ៥៩៨, សង្កាត់បឹងកក់២,ខណ្ឌទួលគោក,ក្រុងភ្នំពេញ | | |


**ការជម្លៀសប្រជាពលរដ្ឋចេញពីលំនៅឋានដោយគ្មានមូលហេតុ គឺជារឿងខុសច្បាប់ !**